អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Mar-2023, 14:18
CMS/CFO: Sann Rada

# អនុស្សរណៈអន្តរការិយាល័យ
# INTEROFFICE MEMORANDUM

**ផ្ញើពី:** **ប្រធានអង្គជំនុំជម្រះតុលាការកំពូល** ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២៣

**(“ប្រធាន”)**

**President of the Supreme Court Chambe**
**(the “President”)**

**ផ្ញើជូន:** **លោក ពេជ អង្គ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

**លោកស្រី Falguni DEBNATH សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

**Mr. PICH Ang, Civil Party Lead Co-Lawyer**

**Ms. Falguni DEBNATH, Civil Party Lead Co-Lawyer**

**ចម្លងជូន** **ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល**

**Judges of the Supreme Court Chamber**

ឯកឧត្តម **ក្រាញ់ តូនី** ប្រធានការិយាល័យរដ្ឋបាលស្ដីទី

លោក **Knut Rosandhaug** អនុប្រធានការិយាល័យរដ្ឋបាល

**H.E. Mr. Tony KRANH**, Acting Director of Administration
**Mr. Knut ROSANDHAUG**, Deputy Director of Administration

**ក្រឡាបញ្ជីអង្គជំនុំជម្រះតុលាការកំពូល**

**Greffiers of the Supreme Court Chamber**

**កម្មវត្ថុ** **សេចក្ដីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលបន្ទាប់ពីទទួលបានការឆ្លើយតបរបស់សហមេធាវីនាំមុខពាក់ព័ន្ធទៅនឹងការបង្ហាញឯកសារទៅភាគីទីបី ឬភាគីដទៃទៀត**

Supreme Court Chamber’s Direction Following Receipt of the Lead Co-Lawyers Response Concerning the Disclosure of Documents to a Third Party or Parties

នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០២២ ប្រធានអង្គជំនុំជម្រះតុលាការកំពូលបានទទួលអនុស្សរណៈផ្ញើពីប្រធាន និងអនុប្រធាននៃការិយាល័យរដ្ឋបាលជូនដំណឹងដល់អង្គជំនុំជម្រះថា ឯកសាររបស់តុលាការប្រមាណ

១.៤០០ ច្បាប់ ត្រូវបាន"បរិច្ចាគ"ទៅឱ្យភាគីទីបីតាមរយៈលោកស្រី Martine JACQUIN ដែលជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៃក្រុមមេធាវី DFS។ នៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០២២ ប្រធានអង្គជំនុំជម្រះបានបង្គាប់ការិយាល័យរដ្ឋបាល និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើការទំនាក់ទំនងជាមួយលោកស្រី Martine JACQUIN អំពីបញ្ហាខាងក្រោម៖ (១) ថាតើមានដីកាបង្គាប់របស់តុលាការណាមួយត្រូវបានចេញដែលអនុញ្ញាតឱ្យលោកស្រីផ្តល់ឯកសារនេះទៅភាគីទីបី ដែរ ឬយ៉ាងណា (២) ថាតើមានការយល់ព្រមជាលាយលក្ខណ៍អក្សរទទួលបានពីកូនក្តីរបស់ខ្លួន ដែរ ឬយ៉ាងណា ប្រសិនបើមាន គប្បីផ្តល់ច្បាប់ចម្លងនោះ (៣) ត្រូវធានាថា រាល់ឯកសារនោះត្រូវប្រគល់ត្រឡប់មក អ.វ.ត.ក. វិញ (៤) ត្រូវពិនិត្យ និងចងក្រងត្រឹមត្រូវរាល់ឯកសារនោះ (៥) ត្រូវរាយការណ៍ជូនប្រធានអង្គជំនុំជម្រះនូវបញ្ជីឈ្មោះពេញលេញនៃឯកសារដែលបានចងក្រង និងលិខិតយល់ព្រម ប្រសិនបើមាន។

ការិយាល័យរដ្ឋបាលបានបញ្ជូនអនុស្សរណៈទៅសហមេធាវីនាំមុខនៅថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០២២ ដោយកត់សម្គាល់ក្នុងចំណោមនោះថា "ឯកសារនោះអាចមានលក្ខណៈរសើប ឬត្រូវបានដាក់ចំណាត់ថ្នាក់ដោយតុលាការជាសម្ងាត់ ឬសម្ងាត់បំផុត។ [..] ការិយាល័យរដ្ឋបាលពុំមែនជាភាគីនៅក្នុងសំណុំរឿងចំពោះមុខ អ.វ.ត.ក." និងបានស្នើសុំថា សហមេធាវីនាំមុខត្រូវអនុវត្តស្របតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះ និងស្នើសុំឯកសារចម្លងនៃការឆ្លើយតបនោះ។

នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០២២ សហមេធាវីនាំមុខបានផ្ញើអនុស្សរណៈមកក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលរាយការណ៍ថា ពួកគាត់បានទំនាក់ទំនងជាមួយក្រុមមេធាវី DFS និងទទួលបានការឆ្លើយតបទៅនឹងសំណួរខាងលើរបស់អង្គជំនុំជម្រះ។

ជាសង្ខេប លោកស្រី Martine JACQUIN បានឆ្លើយតបថា ពុំមានដីកាបង្គាប់របស់តុលាការអនុញ្ញាតឱ្យប្រគល់ឯកសារនោះទេ និងថា ពុំទទួលបានការយល់ព្រមជាលាយលក្ខណ៍អក្សរពីដើមបណ្តឹងរដ្ឋប្បវេណី។ ជាការឆ្លើយតបទៅនឹងការបង្គាប់របស់អង្គជំនុំជម្រះដែលថា ឯកសារដែលត្រូវបានផ្តល់នោះត្រូវប្រគល់ត្រឡប់មក អ.វ.ត.ក. វិញ សហមេធាវីនាំមុខបានរាយការណ៍ថា ក្រុមមេធាវី DFS បានប្រគល់មកវិញនូវឯកសារចំនួនប្រាំពីរប្រអប់ និងប្រាំបួនទូ (ដែលមានសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី) ដាក់ក្នុងបន្ទប់ ២០៦ នៃ អ.វ.ត.ក. កាលពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២២។ ក្រុមមេធាវី DFS បានផ្តល់បញ្ជីឈ្មោះឯកសារ ហើយសហមេធាវីនាំមុខខាងជាតិបានពិនិត្យរាល់ឯកសារដែលបានប្រគល់មកឱ្យ អ.វ.ត.ក. ដោយ

មានវត្តមានលោកស្រី នួន សុជាតា ដែលជាអ្នកសម្របសម្រួលក្រុមមេធាវី DSF។ ក្រុមសហមេធាវីនាំមុខជាតិបានបង្កើតបញ្ជីឈ្មោះឯកសារ (ជាភាសាបារាំង) ដែលមានក្នុងប្រអប់នីមួយៗ ប៉ុន្តែគ្មានការបកប្រែជាភាសាខ្មែរ ឬបារាំងនោះទេ។

ក្នុងអ៊ីមែលចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២២ លោកស្រី នួន សុជាតា អ្នកសម្របសម្រួលក្រុមមេធាវី DSF បានកត់សម្គាល់ថា "មានឯកសារជាច្រើនរបស់ DSF ដែលជាឯកសារការងាររបស់សហមេធាវីនាំមុខ ដូច្នេះគប្បីរក្សាទុកឯកសារនេះក្នុងការិយាល័យមេធាវី"។

អាស្រ័យហេតុនេះ ប្រធានអង្គជំនុំជម្រះបង្គាប់សហមេធាវីនាំមុខឱ្យធានាថា រាល់ឯកសារតុលាការ (ជាពិសេសឯកសារដែលត្រូវបានដាក់លេខ ដូចមានក្នុងបញ្ជីប្រអប់ទាំងប្រាំពីរ) រួមបញ្ចូលទាំងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងទូដាក់ឯកសារទាំងប្រាំបួន ត្រូវរក្សាទុកក្នុងបរិវេណនៃ អ.វ.ត.ក. មិនត្រូវបង្ហាញទៅភាគីទីបី ឬភាគីនានា។ រាល់ឯកសារការងាររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវរក្សាទុកក្នុងការិយាល័យដែលបានស្នើឡើងដោយអ្នកសម្របសម្រួលក្រុមមេធាវី DSF។

On October 17, 2022, the President received a Memorandum from the Acting and Deputy Directors of the Office of Administration (OA), informing him that Ms. Martine JACQUIN, a Civil Party lawyer with the Defense sans Frontière (DFS) had "donated" approximately 1,400 judicial documents to a third party. On November 1, 2022, the President directed the OA and the Civil Party Lead Co-Lawyers (LCLs) to liaise with Ms. JACQUIN about the following: (1) whether any court order was issued to permit her to disclose the documents to a third party; (2) whether written consent was obtained from the clients, and if so, a copy of each consent be provided; (3) ensure that all the documents in question are retrieved and returned to the ECCC premises; (4) carefully inspect and catalogues all the documents; (5) and report to the President with a full list of the catalogued documents and consent letters, if any.

The OA sent a memorandum to the LCLs on November 2, 2022, noting, *inter alia*, that "the documents in question may be sensitive in nature or judicially classified as confidential or strictly confidential; [..] the OA is not a party to the case before the ECCC," requesting that the LCLs act in accordance with the Chamber's direction, and requested a copy of their response.

On November 30, 2022, the LCLs sent a memorandum to the Supreme Court Chamber's Greffiers, reporting that they had liaised with the DFS team and obtained the following responses to the Chamber's aforementioned questions.

In summary, Ms. JACQUIN responded that there were no court orders authorising the disclosure of the documents and that no written consents from the civil parties were obtained. In response to the Chamber's directive that the disclosed documents be retrieved and returned to the ECCC premises, the LCLs report that the DSF team returned seven boxes and nine cabinets of documents (containing Civil Party Application) to the ECCC residual premises (room 206) on November 15, 2022. The DSF team provided a catalogue of documents, and the National side of the LCLs Section inspected all documents that arrived at the ECCC premises in the presence of Ms. Nuon Socheata, the DSF team's coordinator. The National LCLs team created an itemised catalogue (in French) listing the documents contained in each box. At the time, the Khmer and English translations were not completed.

In an email dated November 25, 2022, Nuon Socheata, the DSF team coordinator, noted that "there are a number of DSF documents that are CPLs' paperwork, so it is really appreciated if these documents can be kept in lawyer's offices."

The President hereby directs the LCLs to ensure all judicial documents (particularly those assigned document numbers i.e., the catalogued list box 1-7) including but not limited to Civil Party Applications contained in the nine cabinets shall be stored in the ECCC residual premises, not to be disclosed to any third party or parties. All Civil Party Lawyers' paperwork and working documents shall be kept in their offices as requested by the DSF team coordinator.